សៀវភៅប្រាជ្ញាដ៏អស្ចារ្យ

Robin J Johnson

នៅពេលដែលខ្ញុំភ្ញាក់ពីដំណេកនៅថ្ងៃដំបូងនៃឆ្នាំ 2025 នេះ គំនិតមួយចំនួនបានដំណើរការនៅក្នុងចិត្តរបស់ខ្ញុំ ។ ការក្រោកពីដំណេកជាមួយនឹងគំនិតតែមួយនោះគឺជាការល្អ ប៉ុន្តែជាមួយនឹងគំនិតជាច្រើនដែលរត់ជុំវិញក្នុងខួរក្បាលយើង វាអាចជាការលំបាកបន្តិចក្នុងការចាប់យកអ្វីមួយដើម្បីផ្តោតលើ។ យ៉ាងណាក៏ដោយ ខ្ញុំចាប់បានមួយក្នុងចំណោមនោះ។

ទោះបីជាខ្ញុំបានសញ្ជឹងគិតអំពីអាថ៌កំបាំងដ៏អស្ចារ្យនៃព្រះជាព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ក៏ដោយ ការគិតពីអំពីការលះបង់នូវព្រះជនរបស់ព្រះយេស៊ូវក៏បានបង្ហាញសម្រាប់គ្នាទៅវិញទៅមក ខាងក្រោមនេះគឺជាការពិត៖

- ព្រះវិញ្ញាណបរិសុទ្ធបើកសម្តែង និងលាតត្រដាងការអស្ចារ្យទាំងអស់របស់ព្រះយេស៊ូវ។
- ការលះបង់របស់ព្រះយេស៊ូវ និងបំណងប្រាថ្នាឥតឈប់ឈរ ដើម្បីបង្ហាញព្រះវរបិតា ហើយ គោរពកោតខ្លាចទ្រង់នៅក្នុងអ្វីគ្រប់បែបយ៉ាងទាំងអស់។
- ហើយព្រះវរបិតាទ្រង់អួតអំពីព្រះរាជបុត្រាទ្រង់ ហើយប្រគល់សិរីល្អ ព្រះចេស្តា និងអំណាចដល់ទ្រង់ ដោយដាក់អ្វីៗទាំងអស់ឱ្យចុះចូលនឹងទ្រង់។

ពិតណាស់ ការនេះគឺគួរសមសម្រាប់ថ្ងៃដំបូងនៃឆ្នាំថ្មី។ ហើយប្រធានបទនេះប្រាកដជាត្រូវគិតឲ្យបានច្រើនជាងមុន។ វាពិតជាប្រធានបទដ៏គួរឱ្យរំភើបមួយដើម្បីបន្តនៅពេលផ្សេងទៀត។ សូមលោកអ្នកមើលកន្លែងបន្ទាប់ទៀត ។

កម្រិតប្រាជ្ញាប្រចាំថ្ងៃ

ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលខ្ញុំចាប់ផ្តើមធ្វើនូវទម្លាប់ប្រចាំថ្ងៃរបស់ខ្ញុំ (ជាង 50 ឆ្នាំ) ដែលជាការអានមួយជំពូកនៃកណ្ឌគម្ពីរសុភាសិតជារៀងរាល់ថ្ងៃ ខ្ញុំស្ទើរតែមិនបានបញ្ចប់ការអាន២ខនៃជំពូកទី 1 នៅពេលដែលខ្ញុំ បានដឹងថា តើវិធីណាដែលល្អដើម្បីចាប់ផ្តើមឆ្នាំថ្មី ជាជាងជាស់តឿនអ្នកឱ្យធ្វើដូចគ្នាដែរ ។ ដើម្បីអានជំពូកនៃកណ្ឌគម្ពីរសុភាសិត ជារៀងរាល់ថ្ងៃ ។

របៀបដែលការទាំងអស់បានចាប់ផ្តើម

ប្រាំបីខែបន្ទាប់ពីការប្រែចិត្តជឿរបស់ខ្ញុំ (1970) នៅខែកុម្ភៈបន្ទាប់ ខ្ញុំបានចូលមហាវិទ្យាល័យព្រះគម្ពីរ។ នៅពេលខ្លះក្នុងកំឡុងឆ្នាំទីមួយនៃមហាវិទ្យាល័យ វាគ្មិនមកសួរសុខទុក្ខសិស្ស ហើយឲ្យអានជំពូកនៃសុភាសិត ជារៀងរាល់ថ្ងៃ ។ គាត់បានពន្យល់ថា សៀវភៅសុភាសិតមាន ៣១ ជំពូក។ មួយថ្ងៃ១ជំពូកសម្រាប់១ខែនីមួយៗនៃឆ្នាំដើម្បីអាន ក៏ដើម្បីទទួលបានការជំរុញ ស្អាងទឹកចិត្តដោយការបណ្តុះបណ្តាលប្រាជ្ញាអ្នក។

ខ្ញុំមិនអាចប្រាប់អ្នកបានទេថា តើខ្ញុំបានអានគម្ពីរសុភាសិតទាំងមូលប៉ុន្មានដងមកហើយ។ អ្វីដែលខ្ញុំអាចប្រាប់អ្នកបានគឺថាវាតែងតែថ្មីរាល់តែថ្ងៃ ហើយសូម្បីតែច្រើនឆ្នាំមកហើយព្រះបន្ទូលទាំងនេះ នៅតែលេចចេញមក និងនិយាយមកក្នុងជីវិតរបស់ខ្ញុំតាមវិធីផ្សេងគ្នាដូចដែលអ្នកនិពន្ធចង់ឲ្យដល់អ្នកអាន។

ឆ្នាំនេះខ្ញុំសង្ឃឹមថានឹងបញ្ចប់ការបោះពុម្ពលើកទីមួយនៃការលើកទឹកចិត្តប្រចាំថ្ងៃដោយផ្អែកលើគម្ពីរសុភាសិត។

អត្ថប្រយោជន៍ដ៏ធំសម្បើម

មានរឿងជាច្រើនដែលខ្ញុំអាចនិយាយបានអំពីពរជ័យ និងអត្ថប្រយោជន៍នៃការអានមួយជំពូកក្នុងមួយថ្ងៃ។ ការធ្វើបែបនេះជាមួយនឹងកាលវិភាគនៃការអានគម្ពីរជាប្រចាំ និងសំខាន់របស់អ្នក នឹងប្រាកដជាចម្រើនអ្នក បង្រៀនអ្នកអំពីភាពជាបរិសុទ្ធ និងបង្កើតផលផ្លែដ៏អស្ចារ្យក្នុងជីវិតរបស់អ្នក។

[16] គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅជំរង់ នឹងការបង្ហាត់ខាងឯសេចក្ដីសុចរិត [17] ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះ សំរាប់នឹងធ្វើការល្អគ្រប់មុខ។ ធីម៉ូថេទី២ ៣:១៦-១៧

ឥឡូវនេះ ជាជាងបន្តនិយាយអំពីភាពអស្ចារ្យនៃសុភាសិត ខ្ញុំបានគិតថា វាជាការល្អបំផុតដែលអនុញ្ញាតឱ្យបទគម្ពីរនេះនិយាយដោយសង្ខេបដោយខ្លួនឯងវិញ។ ខ្ញុំបានជ្រើសរើសប្រើព្រះគម្ពីរបរិសុទ្ធ សម្រាប់សិក្សានៅក្នុងករណីនេះ។ ខ្ញុំបានទទួលពរជ័យ និងការលើកទឹកចិត្តយ៉ាងខ្លាំងដោយការអានសុភាសិតក្នុងនេះ រួមជាមួយនឹងមតិយោបល់ ខពន្យល់នានា និងការយល់ដឹងជាច្រើន ដែលអ្នកបកប្រែ និងរៀបចំបានផ្តល់ជូន។

តាមរយៈការណែនាំសៀវភៅនេះ ខ្ញុំសូមដកស្រង់ពីលោក Brian Simmons ដែលគាត់និយាយថា៖ *«ឧទាហរណ៍ ពាក្យភាសាហេព្រើរសម្រាប់ «សុភាសិត» គឺ «ម៉ាហាល» មានន័យពីរ៖ ទីមួយគឺ «ពាក្យប្រស្នា ពាក្យប្រៀបធៀប ឬការប្រៀបប្រដូច ការនិយាយដែលបង្ហាញពីប្រាជ្ញា»។ ប៉ុន្តែអត្ថន័យទីពីរត្រូវបានគេមើលរំលងដោយមនុស្សជាច្រើនដែលពាក្យដូចគ្នា mashal ក៏អាចមានន័យថា "ដើម្បីគ្រប់គ្រង កាន់អំណាច" ឬ "ដើម្បីសោយរាជ្យដោយអំណាច"។*

ហើយ Brian និយាយម្តងទៀតដោយធ្វើអត្ថាធិប្បាយលើ 1: 2 ។

«មានពាក្យភាសាហេព្រើរចំនួនប្រាំមួយ ដែលត្រូវបានបកប្រែថា «ប្រាជ្ញា» នៅក្នុងសៀវភៅសុភាសិត។ ពួកគេខ្លះត្រូវការឃ្លាទាំងមូលជាភាសាអង់គ្លេសដើម្បីបង្ហាញអត្ថន័យ។ ពាក្យដែលប្រើនៅទីនេះគឺ «ខុបម៉ា» chokmah ហើយវាត្រូវបានប្រើប្រាស់ក្នុងសុភាសិតរហូតដល់ ៤២ដង។

[1] នេះជាសុភាសិតរបស់សាឡូម៉ូន ជាព្រះរាជបុត្រានៃដាវីឌ ស្តេចសាសន៍អ៊ីស្រាអែល
[2] សំរាប់ឲ្យបានស្គាល់ប្រាជ្ញា នឹងសេចក្តីប្រៀនប្រដៅ ហើយឲ្យបានយល់អស់ទាំងសេចក្តីដែលត្រូវខាងយោបល់
[3] ក៏សំរាប់ឲ្យទទួលសេចក្តីបង្រៀននៃគំនិតត្រឹមត្រូវនៃសេចក្តីសុចរិត សេចក្តីយុត្តិធម៌ នឹងសេចក្តីទៀងត្រង់
[4] ហើយសំរាប់ឲ្យមនុស្សឆោតល្ងង់មានសេចក្តីឆ្លៀវឆ្លាត នឹងឲ្យមនុស្សកំឡោះមានដំរិះ ហើយនឹងសតិបញ្ញានឹងធឹង
[5] ប្រយោជន៍ឲ្យមនុស្សប្រាជ្ញបានស្តាប់ ហើយចំរើនចំណេះឡើង ឲ្យអ្នកណាដែលមានយោបល់បានដឹងដល់សេចក្តីទូន្មានមាំទាំ
[6] ព្រមទាំងឲ្យបានយល់ពាក្យសុភាសិត នឹងប្រស្នា អស់ទាំងពាក្យរបស់អ្នកប្រាជ្ញ នឹងពាក្យអាថ៌កំបាំងទាំងប៉ុន្មានផង។
[7] សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃដំរិះ តែមនុស្សឥតបើគិត គេមើលងាយប្រាជ្ញា នឹងសេចក្តីប្រៀនប្រដៅវិញ។ សុភាសិត 1:1-7 (TPT)

ដូចដែលអ្នកបានអានខគម្ពីរទាំងនេះ អ្នកអាចនឹងឃើញដូចដែលខ្ញុំបានឃើញដែរ ថាព្រះបន្ទូលមានបន្ទូលដោយឯកឯង។

ជាចុងក្រោយ

ខ្ញុំបានចែកចាយការរំលឹកដាស់តឿននេះនៅកន្លែងជាច្រើនក្នុងរយៈពេលជាច្រើនឆ្នាំ ហើយបានទទួលទីបន្ទាល់ដ៏អស្ចារ្យមួយចំនួនពីមនុស្សដែលបានសាកល្បងនឹងការអានជំពូកនៃសុភាសិតជារៀងរាល់ថ្ងៃ ។ ប្រាកដណាស់ នៅក្នុងការតម្រូវការនៃជីវិត ទាមទារឲ្យមានថ្ងៃដែលមនុស្សម្នាក់អាចនឹងខកខានការអាន។ ប្រសិនបើអ្នកខកខានមួយថ្ងៃគ្រាន់តែចាប់ផ្តើមម្តងទៀតជាមួយនឹងជំពូកដែលត្រូវគ្នាសម្រាប់កាលបរិច្ឆេទនៃថ្ងៃ ។ ឧទាហរណ៍ ថ្ងៃទីពីរនៃខែនេះ អានជំពូកទី 2 ។ ចាប់ផ្តើមថ្ងៃនេះ ហើយទទួលបានពរជ័យដ៏អស្ចារ្យពីព្រះពិត។

ការប្រឈមនេះមិនមែនមានន័យថាស្របបានគ្រប់ការនោះទេ ប៉ុន្តែជាការលើកទឹកចិត្តឲ្យចាប់ផ្តើមមានវិន័យជាមួយនឹងការទទួលរង្វាន់ដ៏អស្ចារ្យ។ ក្តីសង្ឃឹមរបស់ខ្ញុំគឺថា វានឹងក្លាយជាចំណង់ចំណូលចិត្តក្នុងការធ្វើដែលខ្ញុំប្រាកដថាវានឹងមានពេលដែលអ្នកជួបប្រទះនូវពរជ័យពីព្រះ និងការបំផុសគំនិតដែលហូរចេញពីការអានសុភាសិតប្រចាំថ្ងៃ។

ប្រសិនបើអ្នករង់ចាំនៅមាត់ទ្វារនៃប្រាជ្ញា ដោយប្រាថ្នាចង់ឮពាក្យមួយជារៀងរាល់ថ្ងៃ នោះសេចក្តីអំណរនឹងលេចចេញនៅក្នុងខ្លួនអ្នក នៅពេលអ្នកស្តាប់នូវអ្វីដែលខ្ញុំនឹងនិយាយ។ ព្រោះប្រភពនៃជីវិតហូរមកអ្នករាល់ពេលដែលអ្នករកឃើញខ្ញុំ ហើយនេះគឺជាអាថ៌កំបាំងនៃការរីកលូតលាស់នៅក្នុងសេចក្តីរីករាយ និងការពេញចិត្តរបស់ព្រះអម្ចាស់។

សុភាសិត ៨:៣៤-៣៥ [34] មានពរហើយ អ្នកណាដែលស្តាប់អញ ដោយចាំយាមនៅមាត់ទ្វារអញរាល់ថ្ងៃ គឺដែលរង់ចាំនៅក្របទ្វារផ្ទះរបស់អញ [35] ឯតអ្នកណាដែលបានអញ នោះបានជីវិត ក៏នឹងប្រកបដោយព្រះគុណនៃព្រះយេហូវ៉ាដែរ